**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**

ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៥

ជូនចំពោះ ឯកឧត្តម Volker Türk
ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
វិមានប្រជាជាតិ (Palais des Nations)
CH-1211 ហ្សឺណែវ ១០ ប្រទេសស្វីស

**កម្មវត្ថុ៖ សំណើសុំអន្តរាគមន៍ជាបន្ទាន់លើករណីការឃុំខ្លួនដោយខុសច្បាប់ ការធ្វើទារុណកម្ម និងការបញ្ជូនកងទ័ពកម្ពុជាមួយចំនួនតូច ក្នុងចំណោមកងទ័ពចំនួន ២០នាក់ ដោយកងយោធាថៃ។**

ឯកឧត្តមជាទីគោរព

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលស្រឡាញ់សន្តិភាព និងខិតខំប្រឹងប្រែងធានាឱ្យបាននូវសន្តិភាព ស្ថិរភាព និងសុខដុមរមនាក្នុងតំបន់ ព្រោះប្រទេសកម្ពុជាមានប្រវត្តិឆ្លងកាត់សង្គ្រាមជាច្រើនទសវត្សរ៍។ ក្នុងស្មារតីនៃការគោរពគ្នាទៅវិញទៅមក និងការរួមរស់ដោយសន្តិភាព កម្ពុជាបានប្រកាន់ខ្ជាប់យ៉ាងពេញលេញនូវកិច្ចព្រមព្រៀងបទឈប់បាញ់ថ្មីៗនេះ ជាមួយព្រះរាជាណាចក្រថៃ ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការស្វែងរក និងការកសាងសន្តិភាពតាមរយៈការសន្ទនា និងកិច្ចសហប្រតិបត្តិការ ។ កម្ពុជាបានវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ និងសូមសម្តែងការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះសេចក្តីប្រកាសព័ត៌មានរួមដែលចេញដោយរាជរដ្ឋាភិបាលម៉ាឡេស៊ី កម្ពុជា និងថៃ បន្ទាប់ពីកិច្ចប្រជុំពិសេស ដែលរៀបចំដោយនាយករដ្ឋមន្ត្រី Dato' Seri Anwar Ibrahim នៅទីក្រុងពុត្រាចាយ៉ា ប្រទេសម៉ាឡេស៊ី។ ក្រោមគំនិតផ្តួចផ្តើមដ៏សំខាន់របស់ឯកឧត្តមប្រធានាធិបតី Donald J. Trump ដោយមានការចូលរួមពីសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា លោក Phumtham Wechayachai នាយករដ្ឋមន្ត្រីស្តីទីរបស់ប្រទេសថៃ និងសហការរៀបចំដោយសហរដ្ឋអាមេរិក ជាមួយនឹងការចូលរួមយ៉ាងសកម្មពីសាធារណរដ្ឋប្រជាមានិតចិន បានបង្ហាញពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះស្ថានភាពដែលកំពុងកើតមានតាមរយៈមធ្យោបាយការទូត ច្បាប់អន្តរជាតិ និងសាមគ្គីភាពក្នុងតំបន់។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC) សូមគោរពជម្រាបឯកឧត្តមមេត្តាជ្រាប ចំពោះទង្វើខុសច្បាប់របស់កងកម្លាំងប្រដាប់អាវុធថៃ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្ស និងគោលការណ៍យុត្តិធម៌ និងសេចក្តីថ្លៃថ្នូររបស់មនុស្សដែលត្រូវបានទទួលស្គាល់ជាសកល។

បន្ទាប់ពីកិច្ចព្រមព្រៀងបទឈប់បាញ់កម្ពុជា-ថៃ ក្នុងជម្លោះប្រដាប់អាវុធថ្មីៗនេះនៅជិតប្រាសាទព្រះវិហារ និងតំបន់ព្រំដែនជាប់គ្នា កងកម្លាំងយោធាថៃបានឃុំខ្លួនទាហានកម្ពុជា ដែលមានសុខភាពល្អ និងមានសមត្ថភាពពេញលេញចំនួន ២០(ម្ភៃ) នាក់ ដោយខុសច្បាប់នូវ។ ទង្វើនេះបានកើតឡើងបន្ទាប់ពីកិច្ចព្រមព្រៀងឈប់បាញ់ចូលជាធរមាន ហើយដូច្នេះជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើទំនុកចិត្ត និងច្បាប់អន្តរជាតិ។

នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៥ កងទ័ពថៃបានប្រគល់ទាហានកម្ពុជាមកវិញតែចំនួន ២(ពីរ) នាក់ ក្នុងចំណោម ២០នាក់ ប៉ុណ្ណោះ។ ជាអកុសល ទាហានទាំងពីរនាក់ដែលបានប្រគល់មកវិញ ត្រូវបានរកឃើញថាស្ថិតក្នុងស្ថានភាពវិបត្តិផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ៖

- ម្នាក់បានទទួលពិការភាពរាងកាយ
- ម្នាក់ទៀតរងរបួសដោយសារការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដែលសន្មត់ថាជាលទ្ធផលនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តអមនុស្សធម៌ ក្នុងពេលស្ថិតក្នុងការឃុំឃាំង ។

ការពិតទាំងនេះបង្ហាញយ៉ាងច្បាស់ពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើទាហានកម្ពុជាដែលត្រូវបានចាប់ខ្លួន និងជាទម្រង់នៃការធ្វើទារុណកម្ម ការប្រព្រឹត្តអមនុស្សធម៌ និងការមិនផ្តល់ការថែទាំសុខភាព និងការទំនាក់ទំនង ដែលទាំងអស់នេះជាការរំលោភបំពានដោយផ្ទាល់លើលិខិតុបករណ៍ច្បាប់អន្តរជាតិជាច្រើន រួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖

**ក្របខណ្ឌច្បាប់ដែលត្រូវបានរំលោភបំពាន៖**

1. **អនុសញ្ញាទីក្រុងហ្សឺណែវ (១៩៤៩) ជាពិសេស ៖**
   - អនុសញ្ញាទីក្រុងហ្សឺណែវ ទី៣ ទាក់ទងនឹងការប្រព្រឹត្តចំពោះឈ្លើយសឹក៖
     - មាត្រា១៣៖ ការប្រព្រឹត្តបែបមនុស្សធម៌ដោយគ្មានការរើសអើង។
     - មាត្រា១៧៖ ការហាមឃាត់ការធ្វើទារុណកម្ម និងការបង្ខិតបង្ខំ។
     - មាត្រា១១៨៖ ការបញ្ជូនត្រឡប់មកវិញដោយមិនបង្អង់យូរ បន្ទាប់ពីការបញ្ឈប់ជម្លោះប្រដាប់អាវុធ។
2. **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ៖**
   - មាត្រា៣៖ សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។
   - មាត្រា៥៖ សេរីភាពពីការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។
   - មាត្រា៩៖ សេរីភាពពីការឃុំខ្លួនតាមទំនើងចិត្ត។
   - មាត្រា១០៖ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈ។
3. **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ៖**
   - មាត្រា៦៖ សិទ្ធិរស់រានមានជីវិត ។
   - មាត្រា៧៖ សេរីភាពពីការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។
   - មាត្រា៩៖ សិទ្ធិទទួលបានសេរីភាព និងសន្តិសុខ ការការពារពីការចាប់ខ្លួន ឬឃុំខ្លួនតាមទំនើងចិត្ត។
   - មាត្រា១៤៖ សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងដំណោះស្រាយផ្លូវច្បាប់។
   - មាត្រា១០(១)៖ បុគ្គលទាំងអស់ដែលត្រូវបានដកហូតសេរីភាព ត្រូវតែទទួលបានការប្រព្រឹត្តបែបមនុស្សធម៌។
4. **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) ៖**
   - មាត្រា១១៖ សិទ្ធិទទួលបាននូវកម្រិតជីវភាពសមរម្យ រួមទាំងអាហារ និងសម្លៀកបំពាក់។
   - មាត្រា១២៖ សិទ្ធិទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្ត។
5. **អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក (CAT)។**

6. **អនុសញ្ញាសម្រាប់ការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (CED)។**

**សំណើ និងការទាមទារជាបន្ទាន់របស់យើង៖**

1. ការដោះលែង និងបញ្ជូនទាហានកម្ពុជា ១៨នាក់ ដែលនៅសល់ ពីការឃុំឃាំងរបស់ថៃ ឱ្យត្រឡប់មកវិញភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ។
2. ការស៊ើបអង្កេតឯករាជ្យ និងមិនលំអៀងដោយអង្គការសហប្រជាជាតិ ឬស្ថាប័នអន្តរជាតិពាក់ព័ន្ធលើ៖
   - ការចាប់ខ្លួនដោយខុសច្បាប់បន្ទាប់ពីការឈប់បាញ់ ។
   - ការធ្វើទារុណកម្ម របួស ឬការឆ្វេសប្រហែសលើទាហានកម្ពុជាទាំងពីរនាក់ដែលបានបញ្ជូនត្រឡប់មកវិញ ។
3. ការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ការស្តារនីតិសម្បទា និងការគាំទ្រផ្នែកចិត្តសាស្ត្រសម្រាប់ជនរងគ្រោះទាំងអស់។
4. វិធានការគណនេយ្យភាពចំពោះជនល្មើស ដោយអនុលោមតាមច្បាប់អន្តរជាតិ ។
5. នីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ (រួមទាំងអ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម ការឃុំខ្លួនតាមទំនើងចិត្ត និងការបាត់ខ្លួនដោយបង្ខំ) ដើម្បីអន្តរាគមន៍ជាបន្ទាន់ និងធ្វើទស្សនកិច្ចប្រទេស និងបេសកកម្មស្វែងរកការពិតតាមការចាំបាច់ ។
6. OHCHR ទាក់ទងជាបន្ទាន់ ជាមួយរដ្ឋាភិបាលថៃ ដើម្បីអំពាវនាវឱ្យអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

យើងសូមជំរុញឱ្យ OHCHR ដោះស្រាយបញ្ហានេះជាបន្ទាន់ ហើយគាំទ្រកម្ពុជាក្នុងក្នុងការដោះស្រាយចំពោះការរំលោភបំពានទាំងនេះ។ យើងស្វែងរកការសាមគ្គីរបស់ឯកឧត្តមក្នុងការលើកកម្ពស់គោលការណ៍សិទ្ធិមនុស្ស ច្បាប់មនុស្សធម៌អន្តរជាតិ និងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើខុសច្បាប់បែបនេះ។

សូម ឯកឧត្តម ទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ដោយក្តីគោរព,**

**កែវ រ៉េមី**

**ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC)**

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

**អ៊ីម៉ែល៖** cambodianhumanrightscommittee@gmail.com

**លេខទំនាក់ទំនង៖** +៨៥៥ ៧៧ ៦២២ ៩៦៦ ឬ +៨៥៥ ៩៨ ៦២៣ ២៨៦

**Cambodian Human Rights Committee**

**Date:** 1 August 2025

**To: His Excellency Mr. Volker Türk**
United Nations High Commissioner for Human Rights
Office of the United Nations High Commissioner for Human Rights (OHCHR)
Palais des Nations
CH-1211 Geneva 10, Switzerland

**Subject: Urgent Appeal Regarding the Unlawful Detention, Ill-Treatment, and Partial Repatriation of 20 Cambodian Soldiers by Thai Military Armed Forces**

***Excellency,***

The Kingdom of Cambodia is a peace-loving nation with a long history of resilience, having endured decades of conflict and striving tirelessly to secure lasting peace, stability, and regional harmony. In the spirit of mutual respect and peaceful coexistence, Cambodia has fully adhered to the recent Ceasefire Agreement with the Kingdom of Thailand, reaffirming its commitment to finding and building peace through dialogue and cooperation. Cambodia highly values the efforts of the international community and expresses its profound appreciation for the Joint Press Release issued by the Governments of Malaysia, Cambodia, and Thailand, following the Special Meeting chaired, hosted, and witnessed by Prime Minister Dato' Seri Anwar Ibrahim in Putrajaya, Malaysia. Under the significant initiative of President Donald J. Trump, this important initiative attended by Cambodia's Prime Minister Samdech Moha Borvor Thipadei HUN Manet, Thailand's Acting Prime Minister Phumtham Wechayachai, and co-organised by the United States of America with the active participation of the People's Republic of China, demonstrates a shared resolve to pursue a peaceful resolution to the ongoing situation through diplomatic means, international law, and regional solidarity.

The Cambodian Human Rights Committee (CHRC) urgently brings to your esteemed attention a deeply disturbing and unlawful act committed by the Royal Thai Armed Forces in gross violation of international humanitarian law, human rights law, and universally accepted principles of justice and human dignity.

Following a mutually agreed-upon ceasefire between Cambodia and Thailand in the recent armed hostilities near the Preah Vihear Temple and adjacent border regions, **Thai military forces unlawfully detained twenty (20) healthy and fully-capable Cambodian soldiers** under false pretenses. This act occurred *after* the ceasefire was in effect, and thus constitutes a grave breach of trust and of **international law governing armed conflict**.

On **1 August 2025**, the Thai military returned **only two (2)** of the twenty Cambodian soldiers. Tragically, both returned soldiers were found to be in severely deteriorated physical and mental condition:

- One has sustained **physical disability**,
- The other is suffering from **severe psychological trauma and mental disorder**, presumed to be the result of inhuman and degrading treatment while in captivity.

These facts strongly indicate a serious violation regarding captured Cambodian soldiers, their rights, and a pattern of **torture, ill-treatment, and denial of medical care and communication**, all of which are in direct violation of multiple international legal instruments, including but not limited to:

**Legal Framework Violated:**

1. **Geneva Conventions (1949), in particular:**
    - **Third Geneva Convention** relative to the Treatment of Prisoners of War:
        - **Article 13**: Humane treatment without adverse distinction.
        - **Article 17**: Prohibition of torture and coercion.
        - **Article 118**: Repatriation without delay after cessation of active hostilities.
2. **Universal Declaration of Human Rights (UDHR):**
    - **Article 3**: Right to life, liberty, and security of person.
    - **Article 5**: Freedom from torture and cruel, inhuman or degrading treatment.
    - **Article 9**: Freedom from arbitrary detention.
    - **Article 10**: Right to a fair and public hearing.
3. **International Covenant on Civil and Political Rights (ICCPR):**
    - **Article 6**: Right to life.
    - **Article 7**: Freedom from torture and cruel, inhuman or degrading treatment.
    - **Article 9**: Right to liberty and security; protection from arbitrary arrest or detention.
    - **Article 14**: Right to a fair trial and legal recourse.
    - **Article 10(1)**: All persons deprived of liberty shall be treated with humanity.
4. **International Covenant on Economic, Social and Cultural Rights (ICESCR):**
    - **Article11**: Right to an adequate standard of living, including food and clothing.
    - **Article 12**: Right to physical and mental health.
5. **Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment (CAT);**
6. **Convention for the Protection of All Persons from Enforced Disappearance (CED).**

**Our Immediate Demands and Requests:**

1. **Immediate and unconditional release and repatriation** of the remaining 18 Cambodian soldiers in Thai custody.
2. **Independent and impartial investigation** by the United Nations or relevant international bodies into:
    - The unlawful capture after ceasefire.
    - The torture, injury, or neglect inflicted on the two repatriated Cambodian soldiers.
3. **Medical assistance, rehabilitation, and psychological support** for all victims.
4. **Accountability measures** against the perpetrators in accordance with international law.
5. **UN Special Procedures** (including the Special Rapporteurs on Torture, Arbitrary Detention, and Enforced Disappearances) to urgently intervene and conduct country visits and fact-finding missions, as necessary.
6. **OHCHR's urgent communication with the Government of Thailand**, calling for full compliance with its obligations under IHL and IHRL.

We urge the OHCHR to treat this matter with the utmost urgency and to support Cambodia in holding accountable those responsible for these violations. We seek your solidarity in upholding the principles of human rights, international humanitarian law, and justice for victims of such unlawful actions.

Please accept, Excellency, the assurances of our highest consideration.

Respectfully yours,

**Keo Remy**
President
**Cambodian Human Rights Committee (CHRC)**
Phnom Penh, Cambodia
Email: cambodianhumanrightscommittee@gmail.com
Contact: +855 77 622 966 / +855 98 623 286